ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១៣៨/១០-វ៉ាយថិច**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា)**

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៩ ៨៨១ ៤២៤ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក គី តាន់ហុក | ប្រធានរោងចក្រ |
| ២- លោក ចៅ បុងស៊ីហាតា | ប្រធានរដ្ឋបាលក្រុមហ៊ុន |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពយុវជនខ្មែរ**

- **សហជីពយុវជនខ្មែរ ក្រុមហ៊ុន** WHITEX (GARMENTS)

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨១៧ ០៨៣ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ម៉ៃ វឌ្ឍនា អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ

២- លោកស្រី យិន កញ្ញា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣- លោក មុំ សុខមៀន ប្រធានសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ

៤- លោក សៀង ប៉ោលីន លេខាធិការសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ចំនួន ៥ ដុល្លារ ឱ្យបានស្មើៗគ្នា ដល់កម្មករនិយោជិតទាំងអស់។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារ ឱ្យកម្មករណា ដែលទទួលប្រាក់ឈ្នួលលើសពីចំនួន ៥៥ ដុល្លារ រួចហើយនោះទេ លើកលែងតែប្រធានក្រុម ដែលក្រុមហ៊ុនតម្លើងឱ្យចំនួន ៥ ដុល្លារ បន្ថែម។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតកន្លះខែម្តង តាមគោលការណ៍ចាស់។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនបានឯកភាពជាមួយប្រតិភូបុគ្គលិក ចុះជាអនុសញ្ញារួមបើកប្រាក់ឈ្នួលមួយខែម្តង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១១៣០ ក.ប/អក/វ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

THE ARBITRATION COUNCIL

**សវនាការ និង សវនាការពិនិត្យ**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ៤១៦ សសយខ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីកម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៦ ចំណុច លើការទាមទារចំនួន ០៨ ចំណុច។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២ ចំណុចនេះ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាទាំង ០២ ចំណុចនេះបន្ថែមទៀត ហើយជាលទ្ធផលភាគីកម្មករនិយោជិតបានដកចំណុចវិវាទទី២ចេញវិញ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចទី១ នេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- អនុសញ្ញារួម ស្តីពីការបើកប្រាក់ឈ្នួលចុះបញ្ជិកា លេខ ២៥៧ កប/អក/វក ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១០។

២- លិខិតលេខ ១៦១/១០ ប.ស.ស/តល ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ របស់បេឡាជាតិរបបសន្តិសុខសង្គម ជម្រាបមក នាយកក្រុមហ៊ុន Whitex Garments (Cambodia) Co., Ltd ស្តីពីសំណើសុំទូទាត់សំណងសោហ៊ុយព្យាបាលវេជ្ជសាស្ត្រ ចំនួន ១៣៩ ៥០០ រៀល។

៣- លិខិតលេខ ៣០៩/១០ ប.ស.ស/តលវ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១០ របស់បេឡាជាតិរបបសន្តិសុខសង្គម ជម្រាបមក នាយកក្រុមហ៊ុន Whitex Garments (Cambodia) Co., Ltd ស្តីពីសំណើសុំទូទាត់សំណងសោហ៊ុយព្យាបាលវេជ្ជសាស្ត្រចំនួន ២២៨ ២០០ រៀល។

៤- លិខិតលេខ ៣០៨/១០ ប.ស.ស/តលវ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១០ របស់បេឡាជាតិរបបសន្តិសុខសង្គម ជម្រាបមក នាយកក្រុមហ៊ុន Whitex Garments (Cambodia) Co., Ltd ស្តីពីសំណើសុំទូទាត់សំណងសោហ៊ុយព្យាបាលវេជ្ជសាស្ត្រចំនួន ១១៣ ៤០០ រៀល។

៥- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន វ៉ាយ ថិច ហ្គាមេន ខេមបូឌា ចុះបញ្ជិកាលេខ ១១១ ក.ប/អក/អធក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) លេខ ២៦៨០ ពណ.ចបព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរ ក្រុមហ៊ុន Whitex (Garments) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦។

២- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ លេខ ៤៩១ កប/អក/វក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ជំរាបមក លោកប្រធានសហជីពសហជីពយុវជនខ្មែរ ក្រុមហ៊ុន Whitex (Garments) ស្តីពីការសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។

៣- លក្ខន្តិកៈសហជីពយុវជនខ្មែរ ក្រុមហ៊ុន Whitex (Garments) ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយថិច លេខ ១១៣០ ក.ប/អក/ វ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយថិច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧៥២ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧៥៣ កប/អក/វក/លកអ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន វ៉ាយចិច ចាប់បើកដំណើការនៅឆ្នាំ២០០៥។ បច្ចុប្បន្ន ក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបចំនួន ២.០០០ នាក់។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន វ៉ាយចិច ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ កម្មករនិយោជិត ដែលជាសមាជិកសហជីពមានចំនួន ៥៥០ នាក់។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុននេះ នៅមិនទាន់មានភាពតំណាងបំផុតនៅឡើយទេ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ចំនួន ៥ ដុល្លារអាមេរិក ឱ្យបានស្មើៗគ្នាដល់កម្មករនិយោជិតទាំងអស់**

- ភាគីនិយោជកបានបញ្ជាក់ថា ប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិតមានចាប់ពី ៥០ ដុល្លារអាមេរិក រហូតដល់ ១០០ ដុល្លារអាមេរិក។ តួយ៉ាង ប្រាក់ឈ្នួលគោលរបស់ប្រធានក្រុម មានចាប់ពី ៧០ ដុល្លារអាមេរិក រហូតដល់ ១០០ ដុល្លារអាមេរិក។ ចំពោះកម្មករនិយោជិតធម្មតាទទួលបានប្រាក់ឈ្នួលគោលចំនួន ៥០ ដុល្លារអាមេរិក ហើយកម្មករនិយោជិតជំនាញទទួលបានប្រាក់ឈ្នួលគោលចំនួន ៥៥ ដុល្លារអាមេរិក។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅពេលដែលមានសេចក្តីជូនដំណឹង ស្តីពីការតម្លើងប្រាក់ឈ្នួល លេខ ០៤៩ កប/សជណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ និយោជកបានតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិក ជូនកម្មករនិយោជិត ដែលមានប្រាក់ឈ្នួលគោលចំនួន ៥០ ដុល្លារអាមេរិក។ ប៉ុន្តែចំពោះកម្មករនិយោជិត ដែលមានប្រាក់ឈ្នួលគោលចំនួន ៥៥ ដុល្លាអាមេរិករួចហើយនោះ និយោជកមិនតម្លើងជូនទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការតម្លើងនេះមានភាពអយុត្តិធម៌ចំពោះកម្មករនិយោជិតណា ដែលមានប្រាក់ឈ្នួលគោលលើសពី ៥៥ ដុល្លារអាមេរិក ពីព្រោះពួកគាត់ទទួលបានប្រាក់ឈ្នួលទាំងនេះ មុនពេលមានសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ។ ដូចនេះ ក្រោយពេលមានសេចក្តីជូនដំណឹង ពួកគាត់គួរតែទទួលបានអត្ថប្រយោជន៍នេះ ដូចកម្មករនិយោជិត ដែលមានប្រាក់ឈ្នួល គោលចំនួន ៥០ ដុល្លារអាមេរិកដែរ។

- ភាគីនិយោជកបានលើកឡើងថា យោងតាមសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុន ត្រូវបន្ថែមប្រាក់ឈ្នួល ចំនួន ៥ ដុល្លារអាមេរិកដល់កម្មករនិយោជិត ដែលធ្លាប់ទទួលបានប្រាក់ឈ្នួលចំនួន ៥០ ដុល្លារពីមុន ប៉ុន្តែ ក្រុមហ៊ុនមិនជាប់កាតព្វកិច្ចត្រូវបន្ថែមប្រាក់ ៥ ដុល្លារអាមេរិកនេះ ដល់កម្មករនិយោជិតទាំងអស់គ្នាទេ ហើយការតម្លើងប្រាក់ឈ្នួលជូនកម្មករនិយោជិត ក្រៅពីសេចក្តីជូនដំណឹងរបស់ក្រសួង គឺអាស្រ័យទៅលើលទ្ធផលការងាររបស់កម្មករនិយោជិតម្នាក់ៗ និងត្រូវមានការគាំទ្រពីប្រធានផ្នែក និងប្រធានក្រុមហ៊ុន។
- ភាគីនិយោជកបានលើកឡើងថា កម្មករនិយោជិតដែលមានប្រាក់ឈ្នួលគោលចំនួន ៥០ ដុល្លារអាមេរិក ដែលនិយោជកតម្លើងឱ្យចំនួន ៥៥ ដុល្លារអាមេរិក មានប្រមាណ ៥០ នាក់ និងកម្មករនិយោជិតមានប្រាក់ឈ្នួល ៥៥ ដុល្លារអាមេរិក ដែលក្រុមហ៊ុនមិនតម្លើងឱ្យ មានប្រមាណពី ៣០ ទៅ ៤០ នាក់។ និយោជកអះអាងថា ក្រុមហ៊ុនមិនអាចតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិកនេះ តាមការទាម ទារបានទេ គឺនិយោជកអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ភាគីនិយោជក និងភាគីកម្មករនិយោជិតទទួលស្គាល់ថា និយោជកបានបញ្ចូលប្រាក់ទ្រទ្រង់ជីវភាព ចំនួន ៦ ដុល្លារអាមេរិក ទៅក្នុងប្រាក់ឈ្នួលរបស់កម្មករនិយោជិតនីមួយៗរួចហើយ។
- ភាគីកម្មករនិយោជិតបានទទួលស្គាល់ថា ការទាមទារនេះ គឺលើសពីអ្វីដែលមានចែងក្នុងច្បាប់ស្តីពីការងារ។ ប៉ុន្តែ ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិក ជូនកម្មករនិយោជិត ដែលក្រុមហ៊ុនមិនបានតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិក។
- ភាគីក្រុមហ៊ុននៅតែប្រកាន់ជំហរដដែលថា ក្រុមហ៊ុនមិនអាចតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិកនេះ តាមការទាមទាររបស់ភាគីកម្មករនិយោជិតនោះទេ។

## ហេតុផលនៃសេចក្តីសម្រេច

### ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន តម្លើងប្រាក់ឈ្នួល ចំនួន ៥ ដុល្លារអាមេរិក ឱ្យបានស្មើៗគ្នា ដល់កម្មករនិយោជិតទាំងអស់

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោល ចំនួន ៥ ដុល្លារអាមេរិក ដល់កម្មករនិយោជិត ដែលក្រុមហ៊ុនមិនបានតម្លើងឱ្យ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណា ដូចតទៅ:

THE ARBITRATION COUNCIL

ចំណុចទី២ នៃសេចក្ដីជូនដំណឹងលេខ ០៤៩ កប/សជណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ចែងថា " *កំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន ៥៦ (ហាសិបប្រាំមួយ)ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតសាកល្បងពី ១ ខែ ទៅ ៣ ខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៤៥ ដុល្លារ បូកប្រាក់តម្លើង ៥ ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ ដុល្លារ ស្មើ ៥៦ ដុល្លារ)។ ចប់រយៈពេលសាកល្បង កម្មករនិយោជិតពេញសិទ្ធិ ត្រូវទទួលប្រាក់ឈ្នួលអប្បបរមាចំនួន ៦១ (ហុកសិបមួយ) ដុល្លារអាមេរិក ក្នុងមួយខែ (គឺប្រាក់ឈ្នួលអប្បបរមា បច្ចុប្បន្ន ៥០ ដុល្លារ បូកប្រាក់តម្លើង ៥ ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ ដុល្លារ ស្មើ ៦១ ដុល្លារ)។*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សេចក្ដីជូនដំណឹងលេខ ០៤៩ កប/សជណ នេះ គឺបានធានាប្រាក់ឈ្នួលអប្បបរមាចំនួន ៦១ ដុល្លារអាមេរិក ក្នុងមួយខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៥០ ដុល្លារ បូកប្រាក់តម្លើង ៥ ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ ដុល្លារ ស្មើ ៦១ ដុល្លារ) ជូនកម្មករនិយោជិតពេញសិទ្ធិ ពោលគឺមិនបានបង្ហាញអំពីការតម្លើងជូនកម្មករនិយោជិត ដែលមានប្រាក់ឈ្នួលគោលចំនួន ៥៥ ដុល្លារអាមេរិកនោះទេ។ នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរមិនមានវិវាទទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតសាកល្បងទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ក្រោយពេលមានសេចក្ដីជូនដំណឹងលេខ ០៤៩ កប/សជណ មក ក្រុមហ៊ុនបានធ្វើការតម្លើប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិតណាដែលមានពី ៥០ ដុល្លារអាមេរិក ទៅ ៥៥ ដុល្លារអាមេរិក និងបូកប្រាក់ឧបត្ថម្ភជីវភាព ៦ ដុល្លារ ដុល្លារអាមេរិកផងដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកបានអនុវត្តត្រឹមត្រូវតាមសេចក្ដីជូនដំណឹងលេខ ០៤៩ កប/សជណ ក្នុងការផ្ដល់ប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតពេញសិទ្ធិរួចហើយ។

ទន្ទឹមនឹងនេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា មិនមានបទប្បញ្ញត្តិនៃច្បាប់ការងារណាចែងអំពីការតម្លើងប្រាក់ឈ្នួលចំនួន ៥ ដុល្លារអាមេរិក ដល់កម្មករនិយោជិត ដែលមានប្រាក់ឈ្នួលគោល ៥៥ ដុល្លារអាមេរិកក្នុងមួយខែរួចហើយដែរ។ ម៉្យាងទៀត ភាគីក្រុមហ៊ុន និងកម្មករនិយោជិត ក៏ពុំមានធ្វើកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយ ដែលចែងអំពីការតម្លើងប្រាក់ឈ្នួលគោលចំនួន ៥ ដុល្លារអាមេរិក ជូនដល់កម្មករនិយោជិតដែលមានប្រាក់ឈ្នួលគោល ៥៥ ដុល្លារអាមេរិក ក្នុងមួយខែដែរ។ ដូច្នេះ ការទាមទាររបស់កម្មករនិយោជិត គឺជាវិវាទអំពីប្រយោជន៍។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បដិសេធការពិចារណាចំពោះការទាមទារវិវាទអំពីប្រយោជន៍ កាលណាសហជីព ដែលនាំវិវាទនោះមក ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស *(សូមមើលសេចក្ដីបង្គាប់លេខ ៨១/០៤-អេវើហ្គ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ៩៨/០៤-ប្រេគយូនៀន ហេតុផល*

*ចំណុចវិវាទទី៣, លេខ ១១៦/០៩-ស៊ីនតាយ ហេតុផលចំណុចវិវាទទី២-ក និងលេខ ៦៤/១០-សិន តៃ ហេតុផល នៃសេចក្ដីសម្រេច ចំណុចវិវាទទី៣*)។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្ដល់គុណវុឌ្ឍិផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការដោះស្រាយ ។

ម្យ៉ាងវិញទៀត ប្រកាស ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា " *សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្ដីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីជំនួសសេចក្ដីបង្គាប់នេះ*" ។

ផ្អែកលើប្រការ ៤៣ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា បើក្រុមប្រឹក្សាអាជ្ញាកណ្ដាលចេញសេចក្ដីបង្គាប់ ដែលដោះស្រាយវិវាទអំពីប្រយោជន៍ វានឹងក្លាយជាអនុសញ្ញារួមរយៈពេលមួយឆ្នាំ។ ជាទូទៅ អនុសញ្ញារួម ត្រូវបានអនុវត្តចំពោះកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ហើយសិទ្ធិក្នុងការធ្វើកូដកម្មមិនអាចអនុវត្តឡើងសម្រាប់សើរើឡើងវិញនូវអនុសញ្ញារួម នៅពេលដែលអនុសញ្ញារួមនោះមិនទាន់ផុតកំណត់នោះទេ។ (*សូមមើលសេចក្ដីបង្គាប់របស់អាជ្ញាកណ្ដាលលេខ ១៥២/០៨-វិលសិន ហេតុផលចំណុចវិវាទទី២*) ។

ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ចែងថា សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ ។

ក្នុងសំណុំរឿងវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរកឃើញថា សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុនវ៉ាយឌិច មិនទាន់មានភាពជាតំណាងបំផុតក្នុងរោងចក្រទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពនេះមិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការធ្វើជាតំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទអំពីប្រយោជន៍របស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុនទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែលមានប្រាក់ឈ្នួលគោលលើសពី ៥៥ ដុល្លារអាមេរិក ក្នុងមួយខែ ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច ដូចតទៅនេះ:

THE ARBITRATION COUNCIL

# សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត ដែលមានប្រាក់ឈ្នួលគោលលើសពី ៥៥ ដុល្លារអាមេរិក ក្នុងមួយខែ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម តិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈយា**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL